00612136

លេខ/No: D427/1/4

នៅចំពោះមុខអង្គបុរេជំនុំជម្រះ

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក-ក.ស.ច.ស(អ.ប.ជ ៧៥)

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក អៀង សារី

ដាក់ជូន: អង្គបុរេជំនុំជម្រះ

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ៤ ខែតុលា ឆ្នាំ ២០១០

**ឯកសារទទួល**
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 04 / 10 / 2010
ម៉ោង (Time/Heure): 15:50
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: Uch Arun

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយ កសចស ឬ អង្គជំនុំជម្រះ សាធារណៈ / Public

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**ចម្លើយតបរបស់ អៀង សារី ទៅនឹងការសង្កេតរបស់សហព្រះរាជអាជ្ញាទៅលើសំណើរបស់ អៀង សារី សុំបន្ថែមចំនួនទំព័រសម្រាប់បណ្ដឹងឧទ្ធរណ៍ ឬនាំទៅនឹងដីកាដំណោះស្រាយ**

---

**ដាក់ដោយ៖**
**សហមេធាវីរបស់លោក អៀង សារី**
លោក អាង ឧត្ដម
លោក Michael G. KARNAVAS

**ផ្ញើជូន៖**
**អង្គបុរេជំនុំជម្រះ**
ចៅក្រម ប្រាក់ គីមសាន
ចៅក្រម ន័យ ថុល
ចៅក្រម ហ្វួត វុទ្ធី
ចៅក្រម Catherine MARCHI-UHEL
ចៅក្រម Rowan DOWNING

**ផ្ញើជូន៖**
**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោក Andrew CAYLEY

**ក្រុមមេធាវីការពារក្ដីទាំងអស់**

លោក **អៀង សារី** តាមរយៈសហមេធាវីរបស់គាត់ ("មេធាវីការពារក្តី") សូមដាក់ចម្លើយតបនេះទៅនឹងការសង្កេតរបស់ការិយាល័យសហព្រះរាជអាជ្ញា[1]ទៅលើសំណើរបស់មេធាវីការពារក្តី សុំបន្ថែមចំនួនទំព័រកំណត់ដើម្បីប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ[2] ("ការសង្កេត") ។ ថ្មីបើកាលពីថ្ងៃទី ១ តុលា ២០១០ អង្គបុរេជំនុំជម្រះបានអនុញ្ញាតតាមសំណើរបស់មេធាវីការពារក្តីសុំបន្ថែមចំនួនទំព័រកំណត់ក្តី[3] ដែលការណ៍នេះធ្វើអោយសំណើនេះលែងចោទជាបញ្ហាហើយ ប៉ុន្តែវិសាលភាពនៃការសង្កេតរបស់ កសព តម្រូវអោយមេធាវីការពារក្តីធ្វើការឆ្លើយតប។ នៅក្នុងការសង្កេតរបស់ខ្លួន កសព គ្មានអ្វីក្រៅតែពីឆ្លៀតឱកាសដើម្បីប្រើឥទ្ធិពលមកលើ អង្គបុរេជំនុំជម្រះ ទាក់ទងនឹងភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍នេះប៉ុណ្ណោះ។ ចំនុចនេះគឺចាកប្រធានបទនៃការសង្កេតទៅលើសំណើសុំបន្ថែមចំនួនទំព័រ ហើយមិនគួរ អង្គបុរេជំនុំជម្រះ យកមកធ្វើការពិចារណាឡើយ។ មេធាវីការពារក្តី មានសិទ្ធិដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលបានអះអាងថ្មីៗ ហើយនិងកំណត់ត្រាកាលប្បវត្តិ ដែលជាផ្នែកមួយនៃកាតព្វកិច្ចវិរិយភាពរបស់ខ្លួន។

## I. សាវតារ

១. មេធាវីការពារក្តី បានធ្វើសំណើសុំដោយមានសំអាងហេតុថា ដីកាដំណោះស្រាយ លើកឡើងនូវបញ្ហាយុត្តាធិការដែលស្មុគស្មាញជាច្រើន ហើយបញ្ហាទាំងនេះមិនអាចដោះស្រាយអោយបានអស់សេចក្តីត្រឹមចំនួន ៣០ ទំព័របានឡើយ។ ការសង្កេតរបស់ កសព មិនបានដោះស្រាយត្រឹមតែបញ្ហាថា តើការបន្ថែមចំនួនទំព័រគួរត្រូវបានអនុញ្ញាតដែរឬអត់នោះទេ[4]។ កសព បានព្យាយាមបន្ថែមទៀត ដើម្បីដោះស្រាយអំពីភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍ ដោយថ្លែងថា៖ ក. "អបជពុំធ្លាប់បានបញ្ជាក់ ថាតើនៅក្នុងកាលៈទេសៈណា ដែលបណ្តឹងឧទ្ធរណ៍បែបដូច្នេះ [សេចក្តីសម្រេច

[1] *រឿងក្តី អៀង សារី* សំណុំរឿងលេខ 00២/១៧-0៩-២០១០-អវតក/កសចស (អពជ៧៥) សំណើជាបន្ទាន់របស់ អៀង សារី សុំបន្ថែមចំនួនទំព័រ ដើម្បីប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយលើបញ្ហាយុត្តាធិការ ("សំណើ") ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ ២០១០, ឯកសា D427/1/1, ERN: 00607672-00607674 ។

[2] *រឿងក្តី អៀង សារី* សំណុំរឿងលេខ 00២/១៧-0៩-២០១០-អវតក/កសចស (អពជ៧៥) ការអង្កេតរបស់ កសព ចំពោះសំណើរបស់មេធាវីការពារក្តី សុំបន្ថែមចំនួនទំព័រ ដើម្បីប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ("ការអង្កេតរបស់ កសព") ចុះថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ២០១០, ឯកសារ D427/1/2, ERN: 00609966-00609970 ។

[3] *រឿងក្តី អៀង សារី* សំណុំរឿងលេខ 00២/១៧-0៩-២០១០-អវតក/កសចស (អពជ៧៥) សេចក្តីលើសំណើជាបន្ទាន់របស់ អៀង សារី សុំបន្ថែមចំនួនទំព័រសម្រាប់ដាក់បណ្តឹងឧទ្ធរណ៍លើបញ្ហាយុត្តាធិការ ដែលបានលើកឡើងនៅក្នុងដីកាដំណោះស្រាយ ចុះថ្ងៃទី ១ តុលា ២០១០ ឯកសារលេខ D427/1/2, ERN: 00609966-00609970។

[4] ការសង្កេត កថាខណ្ឌ ៩។

បញ្ជាក់យុត្តាធិការ] អាចនឹងទទួលយកបាននោះទេ"[5]។ ខ. "បើសិនជាបញ្ហាស្ដីពីយុត្តាធិការដែលមានបំណងលើកឡើងដោយដើមបណ្ដឹងឧទ្ធរណ៍ណាមួយក៏ដោយ ត្រូវបានបញ្ជាក់ពីពេលមុនដោយសហចៅក្រមស៊ើបអង្កេតហើយថា ដើមបណ្ដឹងឧទ្ធរណ៍នោះ មិនដែលបានជ្រើសរើសធ្វើការប្ដឹងឧទ្ធរណ៍ ពីបញ្ហាយុត្តាធិការនោះតាំងពីដំណាការមុនមកទេ នោះជាលទ្ធផល ពួកគាត់នឹងអស់ពេលក្នុងការលើកឡើងពីបញ្ហាទាំងនោះក្នុងពេលនេះហើយ។[6]" គ. "អៀង សារី មានពេលវេលាកំណត់សាមសិបថ្ងៃសម្រាប់ឱ្យធ្វើការធ្វើការជំទាស់ទៅនឹងដីកាសម្រេចរបស់អង្គបុរេជំនុំជម្រះ"[7]។ ឃ. "អបជ និងអង្គជំនុំជម្រះសាលាដំបូង បានយកមកប្រើយ៉ាងទូលំទូលាយ ក្នុងឱកាសផ្សេងផ្សេងៗគ្នាជាច្រើនចំពោះបញ្ហាទាំងអស់នេះ"[8]។

## II. **ការឆ្លើយតប**

២. សហព្រះរាជអាជ្ញាលើកឡើងថា "អបជ ពុំធ្លាប់បានបញ្ជាក់ ថាតើនៅក្នុងកាលៈទេសៈណា ដែលបណ្ដឹងឧទ្ធរណ៍បែបដូច្នេះ [សេចក្ដីសម្រេចបញ្ជាក់យុត្តាធិការ] អាចនឹងទទួលយកបាននោះទេ [9]"។ ប្រសិនបើអំណះអំណាងនេះត្រូវបានគេទទួលយក នោះវិរិយភាពបង្ហាញថាអ្វីគ្រប់យ៉ាងដែល<u>អាច</u>ចាត់ទុកថាជាការជំទាស់ខាងយុត្តាធិការ <u>ត្រូវតែ</u>លើកយកមកវែកញែក ដូច្នេះហើយការ<u>បន្ថែម</u>ចំនួនទំព័រគឺជារឿងចាំបាច់។

៣. សហព្រះរាជអាជ្ញាមានកំហុសក្នុងការលើកឡើងថា "បើសិនជាបញ្ហាស្ដីពីយុត្តាធិការដែលមានបំណងលើកឡើងដោយដើមបណ្ដឹងឧទ្ធរណ៍ណាមួយក៏ដោយ ត្រូវបានបញ្ជាក់ពីពេលមុនដោយសហចៅក្រមស៊ើបអង្កេតហើយថា ដើមបណ្ដឹងឧទ្ធរណ៍នោះ មិនដែលបានជ្រើសរើសធ្វើការប្ដឹងឧទ្ធរណ៍ ពីបញ្ហាយុត្តាធិការនោះតាំងពីដំណាការមុនមកទេ នោះជាលទ្ធផល ពួកគាត់នឹងអស់ពេលក្នុងការលើកឡើងពីបញ្ហាទាំងនោះក្នុងពេលនេះហើយ[10]"។ ជាថ្មីម្ដងទៀត ការសង្កេតនេះ គឺស្ថិតនៅក្រៅវិសាលភាពនៃការកំណត់ចំនួនទំព័រឯកសារ និងមិនគួរយកមកពិចារណាដោយអង្គ

---

[5] *ដូចយោងខាងលើ* កថាខណ្ឌ ៤។

[6] *ដូចយោងខាងលើ* ។

[7] *ដូចយោងខាងលើ* កថាខណ្ឌ ៦។

[8] *ដូចយោងខាងលើ* កថាខណ្ឌ ៨។

[9] *ដូចយោងខាងលើ* កថាខណ្ឌ 4។

[10] *ដូចយោងខាងលើ* ។

បុរេជំនុំជម្រះឡើយ ។ អង្គបុរេជំនុំជម្រះយល់ឃើញថាមេធាវីការពារក្ដីអាចប្ដឹងឧទ្ធរណ៍ “ប្រសិនបើដីកាដំណោះស្រាយទទួលយកយុត្តាធិការរបស់ *អវតក*[11] ”។ ដីកាដំណោះស្រាយទទួលយកយុត្តាធិការរបស់ *អវតក* ដូច្នេះបណ្ដឹងឧទ្ធរណ៍ គឺអាចទទួលយកបាន ។

៤. ការជំទាស់ទៅនឹងបញ្ហាយុត្តាធិការកាលពីលើកមុន ត្រូវបានធ្វើឡើងដោយមេធាវីការពារក្ដី និងត្រូវបានឆ្លើយតបដោយការកត់សម្គាល់មួយពីក្រឡាបញ្ជី នៅការិយាល័យសហចៅក្រមស៊ើបអង្កេតដែលបានលើកឡើងថា កសចស “នឹងពិចារណាឲ្យបានទាន់ពេលវេលាទៅលើសារណានានា... ដោយសារវាជាផ្នែកមួយនៃការវិភាគផ្នែកច្បាប់ដ៏ពេញលេញ ដែលនឹងត្រូវដាក់បញ្ចូលក្នុងដីកាដំណោះស្រាយ[12]” ។ ដូច្នេះដីកាសម្រេចរបស់ កសចស ជំទាស់ទៅនឹងបញ្ហាយុត្តាធិការទាំងនេះ គឺជាដីកាដំណោះស្រាយ ។ ដូច្នេះ ពេលនេះគឺជាពេលវេលាត្រូវប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងបញ្ហាយុត្តាធិការទាំងនេះ ដោយសារតែគ្មានដីកាណាមួយស្ដីពីបញ្ហាយុត្តាធិការទាំងនេះត្រូវបានចេញនៅដំណាក់កាលពីដើមដំបូងនេះទេ ។ ជាទូទៅបណ្ដឹងឧទ្ធរណ៍ អាចធ្វើឡើងតែនៅពេលដែលដីកាមួយត្រូវបានចេញតែប៉ុណ្ណោះ[13]។ ការមិនអនុញ្ញាតឲ្យមានបណ្ដឹងឧទ្ធរណ៍ប្រឆាំងទៅនឹងបញ្ហាយុត្តាធិការទាំងនេះ គឺជាការប្រើនីតិវិធីមិនត្រឹមត្រូវរបស់អង្គបុរេជំនុំជម្រះ និងអាចនាំឲ្យការគ្រប់គ្រងវិស័យយុត្តិធម៌ឈានទៅរកភាពអាប់អោន។

---

[11] *ករណីលោក អៀង សារី*, សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ៦០) សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់ លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើបណ្ដឹងរបស់ លោក អៀង សារី ប្រឆាំងនឹងការអនុវត្ត ការទទួលខុសត្រូវបទល្មើសព្រហ្មទណ្ឌក្នុងនាមជាថ្នាក់លើ, ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១០, ឯកសារលេខ D345/5/11, ERN: 00528364-00528370។

[12] *ករណីលោក អៀង សារី* ,សំណុំរឿង 002/19-09-2007-ECCC/OCIJ, លិខិតពីក្រឡាបញ្ជីនៅ កសចស មកកាន់មេធាវីការពារក្ដី កម្មវត្ថុ: បណ្ដឹងប្រឆាំងនឹងការអនុវត្តបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិនៅ អវតក, ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១០,ឯកសារ D378/1, ERN: 00511620-00511620។ សូមមើលផងដែរ*ករណី លោក អៀង សារី*, សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក/កសចស, លិខិតពីក្រឡាបញ្ជីនៅ កសចស មកកាន់មេធាវីការពារក្ដី កម្មវត្ថុ: បណ្ដឹងប្រឆាំងនឹងការ អនុវត្តបទឧក្រិដ្ឋដែលមាននៅក្នុងមាត្រា៣ថ្មីនៃច្បាប់ស្ដីពីការបង្កើត អវតក(បទឧក្រិដ្ឋថ្នាក់ជាតិ)នៅ អវតក, ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១០, ឯកសារ ERN: 00534062-00534062។ *ករណីលោក អៀង សារី*, សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក/កសចស, លិខិតពីក្រឡាបញ្ជីនៅ កសចស មកកាន់មេធាវីការពារក្ដី កម្មវត្ថុ: បណ្ដឹងប្រឆាំងនឹងការអនុវត្តនូវការរំលោភយ៉ាងធ្ងន់ធ្ងរនៅ អវតក , ថ្ងៃទី៧ខែឧសភា ឆ្នាំ២០១០, ឯកសារ D379/1, ERN: 00511617-00511617 ។

[13] ឧទាហរណ៍ ប៉ុន្តែបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងការបដិសេធតាមការសន្មត់ អាចធ្វើឡើងបាន នៅពេលដែលគ្មានដីកាឲ្យប្ដឹងឧទ្ធរណ៍ណាមួយ ត្រូវបានចេញ។

៥. សហព្រះរាជអាជ្ញាបកស្រាយវិធាន ៧៥(៣) នៃវិធានផ្ទៃក្នុង ដូច្នេះលោក អៀង សារី មានរយៈពេល៣០ (សាមសិប) ថ្ងៃគិតចាប់ពីថ្ងៃដែលត្រូវបានចោទប្រកាន់ ដើម្បីប្តឹងពីបញ្ហាយុត្តាធិការនៅចំពោះមុខអង្គបុរេជំនុំជម្រះ[14] ។ ប៉ុន្តែជាថ្មីម្តងទៀត ការអះអាងនេះ គឺស្ថិតនៅក្រៅវិសាលភាពនៃការសង្កេតពីការកំណត់ចំនួនទំព័រនៃឯកសារ ហើយអង្គបុរេជំនុំជម្រះមិនត្រូវយកមកពិចារណាឡើយ។ ការបកស្រាយរបស់សហព្រះរាជអាជ្ញា គឺមិនស្របគ្នាទៅនឹងការបកស្រាយរបស់សហចៅក្រមស៊ើបអង្កេត ដែលបានលើកឡើងជាពិសេសទាក់ទងនឹងបញ្ហាយុត្តាធិការភាគច្រើនថាខ្លួននឹងពិចារណាឱ្យបានទាន់ពេលវេលាលើបញ្ហាយុត្តាធិការ នៅពេលចេញដីកាដំណោះស្រាយ[15]។ ការបកស្រាយវិធាន ៧៥(៣) របស់សហព្រះរាជអាជ្ញាបង្ហាញពីភាពខ្វះការគោរពចំពោះសិទ្ធិរបស់ជនជាប់ចោទ ។ កាលពីថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ លោក អៀង សារី ទើបតែត្រូវបានចោទប្រកាន់ និងនាំមកកាន់កន្លែងឃុំខ្លួន ហើយគ្មានហេតុផលណា ក្នុងរយៈពេល៣០ថ្ងៃបន្ទាប់ពីត្រូវបានចោទប្រកាន់ គឺជាពេលវេលា និងមធ្យោបាយគ្រប់គ្រាន់ដែលត្រូវផ្តល់អោយ ដើម្បីរៀបចំការជំទាស់តាមផ្លូវច្បាប់ដ៏ស្មុគស្មាញបែបនេះបានទេ [16]។

---

[14] ការសង្កេត, កថាខណ្ឌទី៦។

[15] *ករណីលោក អៀង សារី*, សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក/កសចស, លិខិតពីក្រឡាបញ្ជីនៅ កសចស មកកាន់មេធាវីការពារក្តី កម្មវត្ថុ: បណ្តឹងប្រឆាំងនឹងការអនុវត្តបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិនៅ អវតក, ចុះថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១០, ឯកសារ D378/1, ERN: 00511620-00511620 ។ លោក អៀង សារី សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក/កសចស, លិខិតពីក្រឡាបញ្ជីនៅ កសចស មកកាន់មេធាវីការពារក្តី កម្មវត្ថុ: បណ្តឹងប្រឆាំងនឹងការអនុវត្តបទឧក្រិដ្ឋដែលមាននៅក្នុងមាត្រា៣ថ្មីនៃច្បាប់ស្តីពីការបង្កើត អវតក(បទឧក្រិដ្ឋថ្នាក់ជាតិ)នៅ អវតក, ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១០, ឯកសារលេខ ERN: 00534062-00534062 ។ ករណីលោក អៀង សារី, សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក/កសចស លិខិតពីក្រឡាបញ្ជីនៅ កសចស មកកាន់មេធាវីការពារក្តី កម្មវត្ថុ: បណ្តឹងប្រឆាំងនឹងការអនុវត្តនូវការរំលោភយ៉ាងធ្ងន់ធ្ងរនៅ អវតក , ថ្ងៃទី៧ខែ ឧសភា ឆ្នាំ២០១០, ឯកសារ D379/1, ERN: 00511617-00511617 ។

[16] មានត្រា៣១(១) នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរដ្ឋាភិបាលកម្ពុជាចែងត្រង់ផ្នែកដែលពាក់ព័ន្ធថា “សិទ្ធិរបស់ជនជាប់ចោទដែលមានចែងក្នុងមាត្រា១៤ និង១៥ នៃកតិសញ្ញាអន្តរជាតិឆ្នាំ១៩៦៦ ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយត្រូវបានគេគោរពនៅទូទាំងដំណើរការនៃការជំនុំជម្រះក្តី ។ សិទ្ធិបែបនេះជាពិសេសរួមមានសិទ្ធិទទួលបាននូវសវនាការមួយត្រឹមត្រូវ និងជាសាធារណៈ សិទ្ធិត្រូវបាន ចាត់ទុកថាគ្មានទោសពីរហូតរកឃើញថាមានពិរុទ្ធ សិទ្ធិជ្រើសរើសមេធាវីដោយខ្លួនឯង សិទ្ធិមានពេលវេលា និងលក្ខណៈគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំការពារខ្លួន សិទ្ធិទទួលបានពេលវេលានិងលក្ខណៈគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំការពារខ្លួន ...” (គូសបញ្ជាក់បន្ថែម) ។ មាត្រា៣៥ថ្មី នៃច្បាប់ស្តីពីការបង្កើត អវតក បានចែងត្រង់ផ្នែកដែលពាក់ព័ន្ធថា “ក្នុងការសម្រេចការ ចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ ជនជាប់ចោទមានសិទ្ធិទទួលបាននូវការធានាជាអប្បរមា និង

៦. សហព្រះរាជអាជ្ញាមានកំហុសក្នុងការលើកឡើងថាអង្គបុរេជំនុំជម្រះ និងអង្គជំនុំជម្រះសាលាដំបូងបានសម្រេចលើបញ្ហាយុត្តាធិការជាច្រើនលើកនៅពេលផ្សេងគ្នា[17]។ អង្គបុរេជំនុំជម្រះមិនបានសម្រេចលើបញ្ហាយុត្តាធិការឡើយ ពីព្រោះបញ្ហានេះមិនត្រូវបានគេដាក់ឱ្យអង្គបុរេជំនុំជម្រះដោះស្រាយនោះទេ[18] ។ តាមពិតអង្គបុរេជំនុំជម្រះបានពន្យារពេលយ៉ាងមានប្រសិទ្ធភាពនូវបណ្ដឹងឧទ្ធរណ៍របស់មេធាវីការពារក្ដី ស្ដីពីការទទួលខុសត្រូវក្នុងនាមជាថ្នាក់លើរហូតទល់តែមានបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាដំណោះស្រាយ ហើយអង្គបុរេជំនុំជម្រះបានលើកឡើងនៅពេលនោះថា "ប្រសិនបើដីកាដំណោះស្រាយ សម្រេចទទួលយកយុត្តាធិការរបស់ អវតក ស្ដីពីការទទួលខុសត្រូវក្នុងបទល្មើសក្នុងនាមជាថ្នាក់លើ ជនត្រូវចោទអាចពិចារណាពីឥទ្ធិពលនៃវិធាន ៦៧(៥) នៃវិធានផ្ទៃក្នុង ដែលចែងស្របគ្នាជាមួយនឹងវិធាន ៧៤(៣)(ក) នៃវិធានផ្ទៃក្នុង[19]"។ គោលការណ៍ដែលបង្កើតឡើងដោយអង្គបុរេជំនុំជម្រះ គឺថាប្រសិនបើដីកាដំណោះស្រាយទទួលយកយុត្តាធិការរបស់ អវតក នោះបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងបញ្ហាយុត្តាធិការ ត្រូវតែអាចទទួលយកបាន ។

៧. អង្គជំនុំជម្រះសាលាដំបូង មិនបានសម្រេចលើបញ្ហានេះឱ្យគ្រប់ជ្រុងជ្រោយនោះទេ ។ មេធាវីការពារក្ដីក្នុងសំណុំរឿង០០១ បានធ្វើការជំទាស់តិចតួចបំផុតចំពោះបញ្ហាយុត្តាធិការនៅ អវតក ។ ហើយដូច្នេះអង្គជំនុំជម្រះសាលាដំបូងបានច្រានចោលនូវការពិភាក្សាចាំបាច់ និងស៊ីជម្រៅអំពីបញ្ហាយុត្តាធិការនៅ អវតក ។ អង្គជំនុំជម្រះសាលាដំបូងថែមទាំងមិនត្រូវបានគេប្ដឹងពីបញ្ហាយុត្តាធិការនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ គោលការណ៍មិនជម្រះពីរដង (*ne bis in idem*) ឬក៏ព្រះរាជក្រឹតលើកលែងទោសលោក អៀង សារី ។ លុះត្រាតែអង្គបុរេជំនុំជម្រះទទួលបានសំណុំរឿង ០០២

ភាពភាពគ្នា អនុលោមតាម មាត្រា១៤នៃអនុញ្ញាអន្តរជាតិ ឆ្នាំ១៩៦៦ ស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដើម្បីទទួលបានវេលា និងលក្ខណៈគ្រប់គ្រាន់ដើម្បីត្រៀមរៀបចំការពារខ្លួន"។ (គូសបញ្ជាក់បន្ថែម) ។

[17] ការសង្កេត កថាខណ្ឌទី៨។

[18] មានតែបញ្ហាដែលទាក់ទងនឹងសហឧក្រិដ្ឋកម្មរួម, គោលការណ៍មិនជម្រះពីរដង (*ne bis in idem*) និងព្រះរាជក្រមលើកលែងទោស ត្រូវបានដាក់នៅចំពោះមុខអង្គបុរេជំនុំជម្រះក្នុងសំណុំរឿង០០២ ។ *ករណីលោក អៀង សារី* សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក/កសចស(អបជ៣៥), សាលដីលើបណ្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាឃុំខ្លួនបណ្ដោះអាសន្នរបស់លោក អៀង សារី, ចុះថ្ងៃទី១៧ ខែតុលា ឆ្នាំ២០០៨, ឯកសារ C22/I/74, ERN: 00232976-00233004។

[19] *ករណីលោក អៀង សារី*, សំណុំរឿង ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ៦០), សាលដីកាលើបណ្ដឹងឧទ្ធរណ៍របស់លោក អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេតលើបណ្ដឹងរបស់ លោក អៀង សារី ប្រឆាំងនឹងការអនុវត្តការទទួលខុសត្រូវក្នុងបទល្មើសព្រហ្មណ្ឌក្នុងនាមជាថ្នាក់លើ, ចុះថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០១០, ឯកសារ D345/5/11, ERN: 00528364-00528370។

ទើបអង្គជំនុំជម្រះសាលាដំបូងអាចពិនិត្យមើល និងសម្រេចឲ្យបានស៊ីជម្រៅលើបញ្ហាយុត្តាធិការនៅ អវតក[20]។

ដូច្នេះ យោងតាមមូលហេតុដែលបានគូសបញ្ជាក់នៅក្នុងសំណើនេះ មេធាវីការពារក្តីស្នើសុំដោយសេចក្តីគោរពដល់អង្គបុរេជំនុំជម្រះ បដិសេធមិនយកមកពិចារណានូវការសង្កេតរបស់ កសព ។

សូមចៅក្រមអង្គបុរេជំនុំជម្រះទទួលយកចម្លើយតបនេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី ៤ ខែ តុលា ឆ្នាំ ២០១០

មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

អាង ឧត្តម Michael G. KARNAVAS

សហមេធាវីរបស់លោក អៀង សារី

[20] វិធាន៨៩(១) ចែងត្រង់ផ្នែកដែលពាក់ព័ន្ធថា "អញ្ញត្រកម្មទាក់ទងទៅនឹង ក)យុត្តាធិការរបស់អង្គជំនុំជម្រះ... ត្រូវលើកឡើងយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃក្រោយពីដីកាដំណោះស្រាយចូលជាស្ថាពរបើមិនដូច្នេះទេ អញ្ញត្រកម្មនោះ មិនត្រូវបានទទួលយកឡើយ"។ ការសង្កេត,កថាខណ្ឌទី៧។